**សុន្ទរកថា**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្រ្តី**

**រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា ជាតំណាងដ៏ខ្ពង់ខ្ពស់**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តី**

**នៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងទិវាគ្រូបង្រៀន ៥ តុលា ២០២៤**

**ក្រោមប្រធានបទ**

**"ការអភិវឌ្ឍគ្រូបង្រៀនគឺដើម្បីអភិវឌ្ឍមូលធនមនុស្ស ឆ្ពោះទៅរក ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"**

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៤

- ឯកឧត្តម លោកជំទាវ គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- សមាជិក សមាជិកាអង្គពិធី ជាទីមេត្រី !

ថ្ងៃនេះ ក្នុងនាមតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានសេចក្តីរីករាយដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូទាំងអស់នៅក្នុងទិវាគ្រូបង្រៀន ៥ តុលា ២០២៤ ដែលបានរៀបចំយ៉ាងឱឡារិកនាពេលនេះ។ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានអនុវត្តបេសកកម្មរបស់ខ្លួនប្រកបដោយជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការងារលើកកម្ពស់គុណវុឌ្ឍិ និងតម្លៃរបស់គ្រូបង្រៀននាពេលកន្លងមក ជាពិសេសការដាក់ចេញនូវកំណែទម្រង់សាលាគរុកោសល្យ ដែលជាកំណែទម្រង់អាទិភាពមួយដើរស្របគ្នាជាមួយនឹងកំណែទម្រង់សាលារៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅ

គ្រប់កម្រិត ព្រមទាំងកំណត់យក "កំណែទម្រង់សាលាគរុកោសល្យ ឆ្ពោះទៅរកចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ជាប្រធានបទនៃការប្រារព្ធទិវាគ្រូបង្រៀននៅក្នុងឆ្នាំនេះផងដែរ។

ខ្ញុំសូមរំឭកឡើងវិញថា **ការបង្កើតទិវាគ្រូបង្រៀនគឺជាការរំឭកគុណគ្រូ** ដែលបានខិតខំប្រឹងប្រែង តស៊ូលះបង់ក្នុងការបង្ហាត់បង្រៀន និងការផ្ទេរចំណេះដឹងតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយដល់កូនៗសិស្ស និស្សិត និងយុវជនគ្រប់ៗរូប ហេតុនេះហើយទើប **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន បានផ្តួចផ្តើមគំនិតបង្កើតទិវាគ្រូបង្រៀនដំបូងនៅកម្ពុជា ដោយកំណត់យកថ្ងៃទី៥ ខែតុលា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាគ្រូបង្រៀននៃព្រះរាជាណាចក្រកម្ពុជា។ ការប្រារព្ធទិវាគ្រូបង្រៀនមានគោលបំណងបំផុសឡើងវិញនូវវប្បធម៌និងប្រពៃណីរបស់សិស្ស និស្សិត និងយុវជន ឱ្យរំឭកនូវគុណូបការៈដ៏ថ្លៃថ្លារបស់គ្រូបង្រៀននៅទូទាំងប្រទេស ដែលបានបូជាកម្លាំងកាយ ចិត្ត ប្រាជ្ញា និងស្មារតី ក្នុងការបង្ហាត់បង្រៀនសិស្សានុសិស្ស និស្សិត ព្រមទាំងជាវិស្វករព្រលឹង ជារៀមច្បងក្នុងការងារអប់រំ ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ការការពារ ការកសាង និងការអភិវឌ្ឍជាតិមាតុភូមិលើគ្រប់វិស័យ។ ការរំឭកគុណគ្រូនិងដឹងគុណគ្រូបានក្លាយទៅជាចលនាជាតិដ៏ផុសផុលមួយ តាមរយៈ ការជួបជុំសិស្សឬអតីតសិស្សដើម្បីប្រារព្ធទិវារំឭកគុណគ្រូនៅតាមសាលារៀន ក៏ដូចជាការបង្កើតឱកាសសម្រាប់ការសួរសុខទុក្ខ និងការជួបជុំជាមួយគ្រូបង្រៀននៅតាមសាលារៀនផងដែរ។

នៅឆ្នាំនេះ ទិវាគ្រូបង្រៀននៅថ្នាក់ជាតិបាននិងកំពុងប្រព្រឹត្តទៅក្រោមប្រធានបទ "**ការអភិវឌ្ឍគ្រូបង្រៀនគឺអភិវឌ្ឍមូលធនមនុស្សឆ្ពោះទៅរកចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**" ដើម្បីបង្ហាញអំពី ទិសដៅគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការចូលរួម និងកសាងមូលដ្ឋានគ្រឹះពាក់ព័ន្ធនឹងការអភិវឌ្ឍគ្រូបង្រៀន តាមរយៈកំណែទម្រង់សាលាគរុកោសល្យគ្រប់ជ្រុងជ្រោយ ស្របតាមខ្លឹមសារនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលបានកំណត់យកអាទិភាពគន្លឹះ៥ គឺ "**មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា**" សម្រាប់ឆ្លើយតបទៅនឹងបដិវត្តកម្មឧស្សាហកម្ម៤.០ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា និងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះដ៏សំខាន់ក្នុងការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ការអភិវឌ្ឍមូលធនមនុស្សដែលមានសមត្ថភាព និងភាពឆ្លើយតបទៅនឹងតម្រូវការនៃមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា គឺជាភាពចាំបាច់ ដែលមិនអាចរំលងបាន និងទាមទារឱ្យក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តកិច្ចការកំណែទម្រង់

អប់រំជាច្រើន ដោយផ្តើមចេញពីកំណែទម្រង់ថ្នាក់ជាតិ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព។

គ្រូបង្រៀនគឺជាភ្នាក់ងារដ៏សំខាន់ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ការបង្កើនគុណភាព និងឧត្តមភាពរបស់គ្រូបង្រៀន គឺជាកត្តាគន្លឹះ ដោយក្រសួងនឹងបន្តកំណែទម្រង់សាលាគរុកោសល្យពេលគឺ ការប្រែក្លាយសាលាគរុកោសល្យ ឱ្យក្លាយទៅជាមជ្ឈមណ្ឌលឧត្តមភាពក្នុងការបណ្តុះបណ្តាល និងរឹត្រឹតការគ្រូបង្រៀនគ្រប់កម្រិត ដើម្បីធានាបាននូវគុណភាព និងឧត្តមភាព ឆ្លើយតបនឹងតម្រូវការក្នុងបរិបទថ្មីនេះ។ ការអភិវឌ្ឍគ្រូបង្រៀន ត្រូវការនូវគោលនយោបាយអប់រំគ្រូបង្រៀនដែលគ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃតម្រូវការអប់រំជាតិ ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការលើកកម្ពស់ឋានៈរបស់គ្រូបង្រៀននៅក្នុងសង្គម។ ហេតុដូចនេះហើយ ទើបគោលនយោបាយស្តីពី គ្រូបង្រៀន ត្រូវបានអភិវឌ្ឍ និងកែលម្អជាបន្តបន្ទាប់ ដើម្បី៖ ១).ទាក់ទាញ និងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ២).ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន ៣).ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ និង ៤).ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។

កំណែទម្រង់ជាបន្តបន្ទាប់ត្រូវបានអនុវត្តក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីធ្វើទំនើបកម្មប្រព័ន្ធអប់រំគ្រូបង្រៀននៅកម្ពុជា មានដូចជា៖

- កម្មវិធីបណ្តុះបណ្តាលដំបូងផ្អែកលើគុណសម្បទា៖ ក្រសួងបានកែលម្អកម្មវិធីបណ្តុះបណ្តាលថ្មីសម្រាប់គ្រូបង្រៀន ដោយសង្កត់ធ្ងន់លើការរៀនផ្អែកលើសមត្ថភាព និងការអភិវឌ្ឍជំនាញសំខាន់ៗលើផ្នែកគរុកោសល្យ ការគ្រប់គ្រងថ្នាក់រៀន និងខ្លឹមសារមុខវិជ្ជា។ កម្មវិធីបណ្តុះបណ្តាលនេះក៏រួមបញ្ចូលទាំងការលើកកម្ពស់អក្ខរកម្មឌីជីថល និងការអប់រំបរិយាបន្នផងដែរ ។
- ការផ្តួចផ្តើមឱ្យមានសញ្ញាបត្របរិញ្ញាបត្រសម្រាប់គ្រូបង្រៀន៖ ក្រសួងបានដាក់ឱ្យប្រើប្រាស់កម្មវិធីបរិញ្ញាបត្រផ្នែកអប់រំ (B.Ed.) ដោយផ្តោតលើការបង្កើនស្តង់ដាគុណវុឌ្ឍិសម្រាប់គ្រូបឋមសិក្សា និងមធ្យមសិក្សា។

- ក្របខណ្ឌនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ ដើម្បីធានាថាគ្រូបង្រៀនបន្តអភិវឌ្ឍជំនាញរបស់ពួកគេពេញមួយអាជីពរបស់ពួកគេ ក្រសួងបានបង្កើតក្របខ័ណ្ឌនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។
- កំណែទម្រង់សាលាគរុកោសល្យ៖ ក្រសួងបានប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបងទៅជា វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង និងប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមួយចំនួនឱ្យក្លាយជាមជ្ឈមណ្ឌលឧត្តមភាពក្នុងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនគ្រប់កម្រិត ដើម្បីធានាបាននូវគុណភាព ឆ្លើយតបនឹងតម្រូវការក្នុងបរិបទថ្មី។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន ១១។

ជារួម ការដាក់ចេញនូវវិធានការគោលនយោបាយដែលសមស្រប ទន់ភ្លន់ និងមានភាពបត់បែន អាចរួមចំណែកយ៉ាងធំធេងដល់កម្មវិធីកំណែទម្រង់វិស័យអប់រំជារួម និងដោយឡែកសម្រាប់ការអប់រំគ្រូបង្រៀន។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ចេញវិធានការគោលនយោបាយ ដូចខាងក្រោម៖

១. ការពិនិត្យឡើងវិញនូវតួនាទីគ្រឹះស្ថានអប់រំគ្រូបង្រៀន

២. ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

៣. ការលើកកម្ពស់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

៤. ការអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០

៥. ការអនុវត្តស្តង់ដាគ្រឹះស្ថានអប់រំគ្រូគំរូ

៦. ការអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់

៧. ការលើកកម្ពស់លក្ខណសម្បត្តិគ្រូសតវត្សទី២១។

ជាមួយគ្នានេះ ក្រសួងនឹងដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់គ្រឹះស្ថានអប់រំគ្រូ ដូចខាងក្រោម៖

១. បង្កើនគុណវុឌ្ឍិគ្រូ កែលម្អកម្មវិធីបណ្តុះបណ្តាល និងវិធីសាស្ត្របង្រៀន

២. លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេស

៣. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

៤. លើកកម្ពស់ភាពជាអ្នកដឹកនាំគ្រប់គ្រង

៥. ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ

៦. ការធានាគុណភាព។

ជាទិសដៅនាពេលអនាគត ក្រសួងនឹង៖

១. ការប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ៤ ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យ ដោយច្របាច់បញ្ចូលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត រួមមាន៖ កណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ តាមគំរូបាត់ដំបង និងរាជធានីភ្នំពេញ ដោយប្រើប្រាស់ថវិការដ្ឋ និងដៃគូអភិវឌ្ឍ

២. ការពិនិត្យឡើងវិញតួនាទីសាលាគរុកោសល្យ និងវិក្រឹតការខេត្ត៖ ដោយផ្តោតលើការធ្វើវិក្រឹតការគ្រូបង្រៀន

៣. ការបណ្តុះបណ្តាលមិនផ្តល់ក្របខណ្ឌ៖ សម្រាប់ជំនួសគ្រូជាប់កិច្ចសន្យា ឈានឆ្ពោះទៅអនុវត្តអាជ្ញាប័ណ្ណគ្រូបង្រៀន (គ្រូបង្រៀនកិច្ចសន្យាពិសេស) សម្រាប់សាលារៀននៅជនបទ និងជួបការលំបាក ដោយប្រើប្រាស់គុណវុឌ្ឍិដូចគ្នា

៤. ការបន្តផ្តល់ឋានៈសាស្ត្រាចារ្យ៖ សម្រាប់គ្រូឧទ្ទេស

៥. ការប្រឹក្សាគរុកោសល្យ៖ ការបណ្តុះបណ្តាលប្រឹក្សាគរុកោសល្យ សម្រាប់ការចុះគាំទ្រដល់គ្រូបង្រៀន

៦. ការលើកកម្ពស់គុណវុឌ្ឍិ៖ ក្រសួងនឹងអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលាចំនួន ១៣០០០នាក់ ក្នុងរយៈពេលពីឆ្នាំ ២០២៤ ដល់ ២០២៧

៧. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ៖ ការលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

៨. ការអប់រំឌីជីថល៖ ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលគ្រូ និងការបណ្តុះបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំ ការបង្កើត APPS សម្រាប់អំណាន ថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង និងសាលាឌីជីថល ដើម្បីឱ្យគ្រូធ្វើស្វ័យសិក្សាដោយខ្លួនឯងតែមកប្រឡងដើម្បីទទួលស្គាល់

៩. មគ្គុទេសក៍ និងការផ្តល់ប្រឹក្សាអាជីព៖ ការរៀបចំមុខងារគ្រូផ្នែកមគ្គទេសក៍អាជីព និងការផ្តល់ប្រឹក្សា ដើម្បីជួយសិស្ស ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ ការសិក្សារៀនសូត្រ និងការអភិវឌ្ឍអាជីព

១០. ការបន្តបណ្តុះបណ្តាលគ្រូអប់រំពិសេស៖ បណ្តុះបណ្តាលគ្រូជំនាញផ្នែក គ ថ្លង់ ពិការភ្នែក និង ខ្សោយសតិបញ្ញា

១១. ការអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង៖ ការបណ្តុះបណ្តាលគ្រូអប់រំពហុភាសា សម្រាប់ជនជាតិដើមភាគតិច (ព្នង កាវ៉ែត គ្រឹង ទំពួន ព្រៅ និង ចារ៉ាយ)។

ដើម្បីចូលរួមអបអរសាទរទិវាគ្រូបង្រៀន ៥ តុលា ២០២៤ រូបខ្ញុំនឹងធ្វើបាឋកថាមួយ ស្តីពី "**កំណែទម្រង់សាលាគរុកោសល្យ ឆ្ពោះទៅរកចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០**" ដោយនឹងបរិយាយបន្ថែមទៀត ពាក់ព័ន្ធនឹងវិធានការគោលនយោបាយ យុទ្ធសាស្ត្រកំណែទម្រង់គ្រឹះស្ថានអប់រំគ្រូ និងទិសដៅអនាគត ដូចបានរៀបរាប់ត្រួសៗខាងលើនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

**សមាជិក សមាជិកានៃអង្គពិធី ជាទីមេត្រី !**

ជាថ្មីម្តងទៀត ដើម្បីឱ្យទិវាគ្រូបង្រៀនកាន់តែត្រូវបានចាត់ទុកជា ទិវាដ៏មានសារៈសំខាន់ ខ្ញុំសូមស្នើដល់ក្មួយៗសិស្សានុសិស្ស និស្សិត និងយុវជន ព្រមទាំងប្រជាពលរដ្ឋគ្រប់រូប គប្បីប្រកាន់ខ្ជាប់នូវកតញ្ញូតាធម៌ តាមរយៈការតបស្នងសងគុណដោយប្រការផ្សេងៗ គ្រប់ពេលវេលា និងគ្រប់មធ្យោបាយ ដែលជាប្រពៃណីដ៏ល្អផូរផង់របស់ជាតិយើង ហើយខ្ញុំសូមឧទ្ទិសឱ្យ "ទិវាគ្រូបង្រៀន ៥ តុលា" នេះ ក្លាយទៅជាទិវាដឹងគុណគ្រូ ដែលស្ថិតនៅជាអមតៈក្នុងបេះដូងរបស់សិស្សានុសិស្ស និស្សិត យុវជន និងប្រជាពលរដ្ឋគ្រប់វ័យ គ្រប់ជំនាន់ និងគ្រប់សម័យកាលតរៀងទៅ។

ជាមួយនេះ ខ្ញុំសូមស្នើដល់លោកឪពុក អ្នកម្តាយ និងអ្នកអាណាព្យាបាលទាំងអស់នៅទូទាំងប្រទេស សូមចូលរួមចំណែកឱ្យកាន់តែសកម្មខ្លាំងក្លាថែមទៀត ក្នុងការជួយអប់រំកូនចៅឱ្យចេះគោរពឱនលំទោន មានចរិយាល្អ មានគុណធម៌ និងចេះដឹងគុណគ្រូ ដោយសារពួកគាត់បានបង្ហាត់បង្រៀនឱ្យកូនចៅរបស់យើងឱ្យមានចំណេះដឹង ជំនាញ សមត្ថភាព ទេពកោសល្យ ដឹងខុស ដឹងត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ យល់ការណ៍ពាក់ជ្រៅ និងកសាងអនាគតបានភ្លឺស្វាង និងរុងរឿង។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះលោកគ្រូ អ្នកគ្រូទាំងអស់នៅទូទាំងប្រទេស ដែលបានខិតខំលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បង្ហាត់បង្រៀនសិស្សឱ្យទទួលបានចំណេះដឹង ជំនាញ

សីលធម៌ ចរិយាធម៌ និងកាយសម្បទារឹងមាំ ដើម្បីក្លាយជាពលរដ្ឋល្អ ជាសសរទ្រូងដ៏រឹងមាំក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យសម្បូររុងរឿង។

ជាទីបញ្ចប់ ក្នុងឱកាសនៃការប្រារព្ធទិវាគ្រូបង្រៀន ក្រោមប្រធានបទ "**ការអភិវឌ្ឍគ្រូបង្រៀនគឺអភិវឌ្ឍមូលធនមនុស្សឆ្ពោះទៅរកចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**" នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៤ នេះ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ បងប្អូន ជនរួមជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និស្សិតទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរគុណ!**